# Living the Lotus

## Buddhism in Everyday Life

2
2026
VOL. 245

















On December 12, 2025, Rev. Yasutoshi Mori retired, having served as the minister of the Bangladesh Dharma Center since 2023, and Rev. Keiichi Akagawa, former director of Rissho Kosei-kai International, was appointed as the new minister.

## The Rissho Kosei-kai Bangladesh Dharma Center Holds Inauguration Ceremony for New Minister

**Living the Lotus**
**Vol. 245 (February 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីរព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្រ របស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំ អនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅ ប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួល បានសុខសន្តិភាព។
អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# រៀនពីមីយ៉ាសាវ៉ាគេនជី (Miyazawa Kenji) ②
# នៅពេលដែលមានអ្នកម្តាយដែលនឿយហត់ដួលស្រូសនៅទិសខាងលិច

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ដូចជាព្រះពោធិសត្វដែលផុសពីផែនពសុធា

ខ្ញុំព្រះករុណាអាត្មាភាពប្រាកដថាអ្នកទាំងអស់គ្នាច្បាស់ជាស្គាល់កំណាព្យរបស់កវីមីយ៉ាសាវ៉ាគេនជី (Miyazawa Kenji) ដែលចាប់ផ្តើមដោយ "Ame ni mo makezu" (មិនចុះចាញ់ភ្លៀង) ។

កាលពីខែមុនខ្ញុំព្រះករុណាអាត្មាភាពបានសរសេរថាអានកំណាព្យនេះទៅមានអារម្មណ៍ដូចជាកំពុងសូត្រធម៌។ នៅទីនេះ ខ្ញុំព្រះករុណាអាត្មាភាពសូមបង្ហាញអត្ថបទទាំងស្រុងក្នុងរចនាបទទំនើបដើម្បីឲ្យងាយយល់។

គាត់មិនចុះចាញ់ភ្លៀង / មិនចុះចាញ់ខ្យល់ / មិនចុះចាញ់ព្រិល ឬកំដៅថ្ងៃក្តៅហែង / គាត់មានរាងកាយមាំមួន / គ្មានចិត្តលោភលន់/ មិនចេះខឹង /តែងតែញញឹមយ៉ាងស្ងប់ស្ងាត់ / មួយថ្ងៃគាត់ហូបបាយសំរូបបួនពែងជាមួយនឹង / ទឹកសំឡសៀងនិងបន្លែបន្តិចបន្តួច/ គ្រប់រឿងទាំងអស់ /គាត់មិនដែលគិតខ្លួនឯងជាមុនឡើយ / គាត់មើលស្តាប់ឃើញហើយ ឮ យល់/ រួចហើយចងចាំមិនដែលភ្លេចអ្វីទាំងអស់ / គាត់រស់នៅក្នុងព្រៃស្រល់ក្នុងផ្ទះខ្ទមប្រក់ចំបើងតូចមួយ / បើមានកូនក្មេងម្នាក់ឈឺនៅទិសខាងកើត / គាត់នឹងរត់ទៅមើលថែទាំវា/បើមានអ្នកម្តាយណាដែលហត់នឿយដួលស្រូសនៅទិសខាងលិច / គាត់រត់ទៅជួយលើកពុនកួរស្រូវជំនួសគាត់ / បើមានមនុស្សឈឺជិតស្លាប់នៅទិសខាងត្បូង / គាត់នឹងទៅឱបក្រសោបហើយប្រាប់គេថាកុំភ័យកុំខ្លាច / បើមានជម្លោះ ឬការប្តឹងផ្តល់នៅទិសខាងជើង /គាត់នឹងប្រាប់ពួកគេឱ្យឈប់ឈ្លោះប្រកែកព្រោះវាគ្មានអ្វីគួរឲ្យសប្បាយទេ / នៅពេលថ្ងៃក្តៅខ្លាំងគាត់ស្រក់ទឹកភ្នែក / នៅថ្ងៃរងារនារដូវក្តៅគាត់ដើរតត្រុក/អ្នកផងហៅគាត់ថាមនុស្សចាញ់/ គេមិនសរសើរតែមិនធ្វើទារុណកម្ម/ក៏ប៉ុន្តែខ្ញុំចង់ក្លាយទៅជាមនុស្សបែបនេះ ។»

គឺជាកំណាព្យដែលបង្ហាញយ៉ាងស្មោះត្រង់ពីការប្តេជ្ញាចិត្តផ្អែកទៅលើជំនឿទៅលើព្រះពុទ្ធសាស នារបស់គេនជីដែលខ្ញុំព្រះករុណាអាត្មាភាពអាចបានត្រឹមតែឧទានថា"អស្ចារ្យណាស់" ប៉ុណ្ណោះ។ អ្វីដែលល្អលើសលប់នោះគឺល្បះដែលសរសេរថា «ទៅ» ទិសទាំង៤ គឺ ខាងកើត ខាងលិច ខាងជើង និងខាងត្បូងធ្វើអ្វីដែលខ្លួនអាចធ្វើបាន ។ គឺជាការសន្យាមួយថានឹងអនុវត្តសកម្មភាពជាក់លាក់ ដូចជាការប្រញាប់ប្រញាល់ទៅជួយកុមារដែលកំពុងតែមានជម្ងឺ,ទៅសម្រាលបន្ទុកស្ត្រីជាមាតាកុមារតូចៗដែលហត់នឿយហើយដួលដោយការងារស្រែចំការដ៏លំបាក ទៅប្រាប់ការពិតនៃជីវិតដល់អ្នកដែលដេករង់ចាំសេចក្តីស្លាប់នៅលើគ្រែរបស់ពួកគេ និងធ្វើឱ្យជម្លោះបានស្ងប់ស្ងាត់ ដោយលើកទឹកចិត្តឱ្យមានការផ្សះផ្សារវាងអ្នកដែលកំពុងតែមានក្តីក្តាំនឹងគ្នា។គឺជាសេចក្តីសច្ចា ដោយគិតអំពីការឈឺចាប់របស់អ្នកដទៃ ដោយគ្រាន់តែ "ទៅ" ទីនោះ ហើយធ្វើអ្វីដែលគាត់អាចធ្វើបាន។ យើងអាចឃើញការតាំងចិត្តយ៉ាងមុតមាំថា នេះជាបេសកកម្មរបស់អ្នកដែលប្រតិបត្តិទង្វើព្រះពោធិសត្វក្នុងពិភពសាហា(ពិភពមនុស្សបុថុជ្ជន)ពិតៗ។

នៅក្នុងសៀវភៅកូនការណេត៍សម្រាប់កត់ត្រាហេតុការណ៍ផ្សេងៗរបស់គេនជីបន្ទាប់ពីកំណា ព្យនេះយើងឃើញមានគំនូរមន្ត្រឬយន្ត្រព្រះធម៌បទុមសូត្រដែលមានសរសេរឃ្លាដំបូងថា«យើងខ្ញុំសូមជ្រកកោនក្រោមម្លប់ព្រះធម៌»នៅចំកណ្តាល ហើយនៅសងខាងឃ្លានោះមានព្រះឆាយាព្រះតថាគតប្រភូរតន៍និងព្រះសម្មាសម្ពុទ្ធហើយនៅជុំវិញមានព្រះពោធិសត្វទាំងបួនព្រះអង្គគឺព្រះពោធិសត្វសួគិមតិ (Jogyo), ព្រះពោធិសត្វអនន្តាគតិ（Muhengyō）ព្រះពោធិសត្វសុទ្ធមតិ(Jogyo)និងព្រះពោធិសត្វផ្សព្វផ្សាយព្រះធម៌(Anryūgyo)។ ព្រះពោធិសត្វទាំង ៤ ព្រះអង្គនេះឯងហើយជាមគ្គុទេសនៃព្រះពោធិសត្វទាំង ឡាយដែលផុសចេញពីព្រះធរណីជាអ្នកបំពេញបំណងរបស់ព្រះពុទ្ធហើយជាអ្នកសង្គ្រោះសត្វលោកទាំងអស់ឱ្យរួចពីទុក្ខពិតៗ។ ខ្ញុំព្រះករុណាអាត្មាភាពជឿថាមានចំណុចជាច្រើនដែលយើងអាចរៀនសូត្រពីអាកប្បកិរិយារបស់ព្រះពោធិ សត្វទាំងឡាយនេះក្នុងការគិតអំពីអ្វីដែលយើងអាចធ្វើបានក្នុងការជួយលួងលោមសម្រាលទុក្ខអ្នកដទៃ។

## "គាត់ខំមើលស្តាប់បានឃើញបានឮហើយយល់"

ម្យ៉ាងទៀត រាល់ពេលដែលខ្ញុំព្រះករុណាអាត្មាភាពអានកំណាព្យត្រង់ គាត់មិនដែលគិតពីខ្លួនឯងជាមុនឡើយគាត់ខំមើលស្តាប់បានឃើញបានឮហើយយល់ ខ្ញុំព្រះករុណាអាត្មាភាពតែងតែគិតថានេះជាអ្វីដែលអ្នកទាំងអស់គ្នារួមទាំងប្រធានសាខានិងប្រធានសមាគមយើងអនុវត្តជាប្រចាំ។យើងស្តាប់ការត្អូញត្អែរនិងការទួញសោករបស់អ្នកដទៃដោយស្ងៀមស្ងាត់មិនបញ្ចេញយោ បល់ឬគំនិតផ្ទាល់ខ្លួនកាត់ពាក្យសម្តីគេដោយ សារតែយើងជឿលើធាតុព្រះពុទ្ធរបស់អ្នកនោះ។ នេះជាឱកាសដ៏វិសេសដែលអាចជួយបុគ្គលដទៃឲ្យរកផ្លូវរួចផុតពីទុក្ខកង្វល់ហើយជាការប្រតិបត្តិទង្វើព្រះពោធិសត្វដ៏ខ្ពង់ខ្ពស់ ។ នៅពេលដែលយើងស្តាប់ការត្អូញត្អែឬការរអ៊ូរទាំនិងការទួញសោកប្រកបដោយក្តីមេត្តាពួកគេនឹងយល់ដោយស្វ័យប្រវត្តិនូវអ្វីដែលធ្វើឱ្យពួកគេឈឺចាប់និងមូលហេតុរបស់វាហើយបេះដូងរបស់ពួកគេនឹងបានធូរស្រាល ហើយពួកគេនឹងឈានទៅដល់ផ្លូវចេញពីភាពលំបាកបាន។

នៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពទៅធ្វើទស្សនកិច្ចនៅតំបន់មួយដែលជម្លោះជនជាតិភាគតិចដោយសារសង្គ្រាមស៊ីវិលនៅតែអូសបន្លាយ ហើយបានជួបជាមួយមេដឹកនាំសាសនាសំខាន់ៗក្នុងតំបន់ ប្រហែលជាដោយសារឥទ្ធិពលកំណាព្យរបស់គេនជីហើយមើលទៅខ្ញុំព្រះករុណាអាត្មាភាពបានខំស្តាប់គេនិយាយរៀបរាប់ដោយស្ងៀមស្ងាត់។ ប៉ុន្តែបន្តិចម្តងៗ បរិយាកាសនៃការពិភាក្សាបានចាប់ផ្តើមវិវត្តក្នុងចំណោមប្រជាជន ដែលមុននេះពួកគេបង្ហាញភាពស្ងៀមស្ងាត់មិនចង់និយាយស្តីជាមួយយើងសូម្បីតែមួយម៉ាត់។

ខ្ញុំព្រះករុណាអាត្មាភាពគិតថាដូចជាមានអ្វីមួយដែលដូចជាព្រះឬព្រះពុទ្ធគង់នៅក្នុងចិត្តរបស់មនុស្សម្នាក់ៗធ្វើឱ្យពួកគេបញ្ចេញអារម្មណ៍របស់ពួកគេថា"ការប្រយុទ្ធមិនមែនជាការសប្បាយរីករាយទេ"។

នៅពេលដែលគ្រលៀសភ្នែកមើលទៅពិភពលោកយើងនឹងឃើញថាអ្នកដែលមានសេចក្តីទុក្ខសោកខ្លាំងក្លាមានច្រើនលើសលុបដែលយើងមិនដឹងជាអាចជួយអ្វីកើត។យើងក៏មានអារម្មណ៍ថាយើងជាមនុស្សចាញ់ដែលគ្មានប្រ យោជន៍ចំពោះនរណាសោះ។តែទោះបីជាយ៉ាងនេះក្តីគេនជីបានបង្រៀនយើងឱ្យរក្សាទស្សនៈទូលំទូលាយ រាប់អានមនុស្សដោយចិត្តគោរព ឱ្យមានទឹកចិត្តល្អ និងកក់ក្តៅ។ - ចូរអ្នកកុំភ្លេចថាការអនុវត្តប្រចាំថ្ងៃតូចតាចដែលមិនមាននរណាចាប់ភ្លឹកឬកត់សម្គាល់អាចជាឫសគល់បន្តផ្ទាប់ទៅនឹងបញ្ហានៃសកលលោកហើយសូមកុំធ្វេសប្រហែសក្នុងការប្រតិបត្តិក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

『កូសេ』 ខែកុម្ភៈ ២០២៦






# A Global Buddhist Movement




## Information about local Dharma centers

facebook

X

✉ We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)